ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# មហាសន្និបាតលើកទី ២៥

# របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

# របាយការណ៍

## ស្តីពី

## វឌ្ឍនភាពការងាររយៈពេល១ ឆ្នាំ របស់គណៈមេធាវី

## នៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី ១២

## ខែតុលា ឆ្នាំ២០១៩ - ខែតុលា ឆ្នាំ២០២០

**មាតិកា** **ទំព័រ**


សេចក្តីផ្តើម ........................................................................... ១

១- សកម្មភាពការពារក្តីជូនជនក្រីក្រ ........................................... ៣

២- ការបណ្តុះបណ្តាលមេធាវី........................................................ ៥

៣- ការផ្សព្វផ្សាយ អប់រំច្បាប់ និងការពង្រឹងសមត្ថភាពមេធាវី ........................ ៦

៤- គោលនយោបាយមូលនិធិសុខុមាលភាពរបស់មេធាវី........................... ៦

៥- ការធ្វើទំនើបកម្មប្រព័ន្ធទំនាក់ទំនងក្នុងក្របខណ្ឌស្ថាប័នគណៈមេធាវី .................. ៧

៦- ប្រសិទ្ធភាពការងាររបស់ប្រតិភូគណៈមេធាវីប្រចាំរាជធានី-ខេត្ត.......................... ៧

៧- ការបង្កើតឱ្យមានបន្ទប់មេធាវីជួបប្រាស្រ័យកូនក្តីតាមពន្ធនាគារ រាជធានី-ខេត្ត ....... ៨

៨- ការផ្តល់មេធាវីជួយការពារក្តីក្នុងយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿង ..........៩

៩- ការធ្វើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ...................................................៩

១០-ការសម្រេចឱ្យមានអាវវិជ្ជាជីវៈមេធាវីសម្រាប់ថ្នាក់ដឹកនាំគណៈមេធាវី................ ១០

១១- ការចូលរួមជាមួយនឹងរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃកូវីដ ១៩.. ១០

១២- ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងគណៈមេធាវី និង ក្រសួង ស្ថាប័នរដ្ឋ ព្រមទាំងដៃគូជាតិ និងអន្តរជាតិនានា ........................................................................ ១១

១៣- ការបង្កើតគណៈកម្មការកីឡាគណៈមេធាវី................................................. ១២

១៤- ការបង្កើតបទភ្លេងអត្តសញ្ញាណគណៈមេធាវី .............................................. ១២

១៥- ការចុះអនុស្សរណៈយោគយល់រវាងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងសភាពាណិជ្ជកម្មកម្ពុជា .................................................................................. ១៣

១៦- គណៈកម្មការវិន័យនៃក្រុមប្រឹក្សាគណៈមេធាវី.............................................. ១៣

១៧- ការទទួលបានអគារទាំងមូលសម្រាប់គណៈមេធាវី ..........................................១៤

១៨- ការកំណត់ពីការប្រើប្រាស់ត្រារបស់ការិយាល័យមេធាវី ក្រុមមេធាវី និងក្រុមហ៊ុនមេធាវី ........................................................................................... ១៥

១៩- ការចូលរួមក្នុងសកម្មភាពសង្គម ................................................................ ១៦

បញ្ហាប្រឈមដែលគណៈមេធាវីពើបប្រទះ ................................................ ១៧

ទិសដៅអនុវត្តបន្ត....................................................................... ១៩

សេចក្ដីសន្និដ្ឋាន....................................................................... ២២

# សេចក្តីផ្តើម



គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាអង្គការប្រមូលផ្តុំមេធាវីទាំងអស់ដែលតាំងការិយាល័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ វិជ្ជាជីវៈមេធាវីជាវិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបម្រើវិស័យយុត្តិធម៌។

ដោយសារសុខសន្តិភាពនិងស្ថិរភាព សង្គម ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់ **សម្តេចតេជោប្រមុខរាជរដ្ឋាភិបាល** គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានទទួលការឧបត្ថមផ្ទាល់ជាបន្តបន្ទាប់ពី **សម្តេចតេជោ** ក្នុងដំណាក់កាល នៃការចាប់ផ្តើមដំបូង ដើម្បីឱ្យស្ថាប័នមួយនេះអាចដំណើរការការងាររបស់ខ្លួនបាន រហូតមានឱកាស អភិវឌ្ឍខ្លួនឯងបន្តិចម្តងៗ ដោយទទួលបាននូវលទ្ធផលគួរជាទីមោទនៈ។

លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានមហាសន្និបាតគណៈមេធាវីលើកទី២៣ បោះឆ្នោតជ្រើសតាំងជាប្រធានគណៈមេធាវីបន្តសម្រាប់អាណត្តិទី១២ កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨។ រយៈពេល២ឆ្នាំចុងក្រោយនេះ លោក មេធាវី សួន វិសាល បានលះបង់ពេលវេលានិងកម្លាំងកាយ ចិត្ត ប្រាជ្ញា ស្មារតី បំពេញការងារក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងគោលដៅពង្រឹងវិជ្ជាជីវៈមេធាវី ជាពិសេស ពង្រឹងសាមគ្គីភាព និងការទទួលខុសរបស់មេធាវីក្នុងការបម្រើយុត្តិធម៌សង្គម។

ក្នុងអាណត្តិទី១២នេះ លោកមេធាវី សួន វិសាល បានខិតខំប្រឹងប្រែងបន្តអនុវត្តគោលនយោបាយដឹកនាំដែលបានដាក់ចេញនាពេលកន្លងមក និងបានកំណត់នូវគោលការណ៍ដឹកនាំថ្មីៗបន្ថែមទៀត ដើម្បីសម្រេចបាននូវសមិទ្ធផលថ្មី និងដើម្បីលើកកម្ពស់កិត្យានុភាពគណៈមេធាវី និងវិជ្ជាជីវៈមេធាវី ពង្រឹងសាមគ្គីភាពផ្ទៃក្នុង សេចក្តីថ្លៃថ្នូរ និងក្រមសីលធម៌មេធាវី ជាពិសេសធានាឱ្យបាននូវផលប្រយោជន៍មេធាវី និងការទទួលស្គាល់តួនាទីមេធាវីក្នុងសង្គម ទាំងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ។

សមិទ្ធផលថ្មីៗទាំងនោះ មានជាអាទិ៍ ការពង្រឹងយន្តការជួយការពារក្តីជូនជនក្រីក្រ ការរៀបចំដំណើរការនៃការផ្ទេរអគារនៃមជ្ឈមណ្ឌលតម្កល់ឯកសារសាលាក្តីខ្មែរ មកស្ថិតក្រោមការគ្រប់គ្រងពេញលេញរបស់គណៈមេធាវី ការសាងសង់ស្ថាពរនូវបន្ទប់ប្រឹក្សាយោបល់ជាមួយកូនក្តី

នៅតាមពន្ធនាគារ ការសម្រេចលើអាវវិជ្ជាជីវៈមេធាវី និងអាវសម្រាប់មេធាវីប្រើប្រាស់ក្នុងកម្មវិធីផ្លូវការរបស់គណៈមេធាវី ការពង្រឹងសមត្ថភាពមេធាវីកម្មសិក្សា ការទទួលបានថវិកាបន្ថែមរហូតដល់ចំនួន១២០០លានរៀលពីរាជរដ្ឋាភិបាលសម្រាប់ការពារក្តីជូនជនក្រីក្រ ក្នុងឆ្នាំ២០១៩ និងចំនួន១៦០០លានរៀលក្នុងឆ្នាំ២០២០ ការបង្កើតឱ្យមានគណៈកម្មការវិន័យ ការធ្វើទំនើបកម្មកម្មវិធីសិក្សាសម្រាប់សិស្ស និងសិក្ខាកាមមេធាវី ការបណ្តុះបណ្តាលបន្ត ដើម្បីពង្រឹងសមត្ថភាពមេធាវី ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិនានា ការរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយតាមរយៈមេធាវីជាអន្តរការី និងការធ្វើទំនើបកម្មកិច្ចការងារក្នុងក្របខ័ណ្ឌគណៈមេធាវី ដូចជា ការងារអធិការកិច្ច ការគ្រប់គ្រងសំណុំរឿងក្តីជនក្រីក្រដោយប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យា និងការធ្វើទំនើបកម្មការបំពេញការងាររដ្ឋបាលទូទៅតាមបែបព័ត៌មានវិទ្យា ការរៀបចំជួសជុលកែលម្អអតីតអគារនៃមជ្ឈមណ្ឌលតម្កល់ឯកសារសាលាក្តីខ្មែរក្រហមមកជាបន្ទប់សម្រាប់ប្រើប្រាស់បំពេញការងាររបស់គណៈមេធាវី ការសាងសង់អាហារដ្ឋានគណៈមេធាវី ការសហការជាមួយក្រសួងយុត្តិធម៌ក្នុងការងារពង្រឹងយុត្តិធម៌សង្គមតាមរយៈយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតុលាការ ការសហការជាមួយសភាពាណិជ្ជកម្មកម្ពុជាក្នុងការងារពង្រឹងវិស័យពាណិជ្ជកម្មនិងសេវាកម្មច្បាប់ ការរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាលក្នុងសកម្មភាពទប់ស្កាត់ និងបង្ការការរាតត្បាតនៃមេរោគ covid-19 ការអនុញ្ញាតឱ្យបណ្តុះបណ្តាលសិស្សមេធាវីតាមអនឡាញដើម្បីឆ្លើយតបនឹងស្ថានភាពឆ្លងនៃមេរោគ covid-19 ការរៀបចំដំណើរការនៃទីលំនៅវិជ្ជាជីវៈរបស់សហភាតាឲ្យកាន់តែមានភាពងាយស្រួល និងប្រកាន់ខ្ជាប់នូវវិធានវិជ្ជាជីវៈ ការកំណត់បន្ថែមអំពីទម្រង់នៃការប្រកបវិជ្ជាជីវៈ និងការបង្កើតក្រុមការងារសិក្សាលើក្រមមូលដ្ឋានទាំងបួន ដើម្បីស្នើទៅក្រសួងយុត្តិធម៌រៀបចំសេចក្តីព្រាង វិសោធនកម្ម។

លទ្ធផលខាងលើនេះ កើតចេញពីកម្លាំងប្រមូលផ្តុំ និងឆន្ទៈមោះមុតរបស់ប្រធានគណៈមេធាវី ក្រុមប្រឹក្សាគណៈមេធាវី អគ្គលេខាធិការ នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី និងបុគ្គលិកគណៈមេធាវីទាំងអស់ ជាពិសេស ការចូលរួមរបស់សមាជិក-សមាជិកា គណៈមេធាវីទាំងអស់។

# របាយការណ៍
# ស្ដីពី
# វឌ្ឍនភាពការងាររយៈពេល ១ ឆ្នាំ របស់គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី ១២

## ១- សកម្មភាពការពារក្តីជូនជនក្រីក្រ

បច្ចុប្បន្នគណៈមេធាវីមានមេធាវីស្ម័គ្រចិត្តចំនួន ២៥៣ រូប ការពារក្តីជូនជនក្រីក្រនៅទូទាំងប្រទេស។ ក្នុងឆ្នាំ២០២០នេះ គិតត្រឹមបំណាច់ត្រីមាសទី២ គណៈមេធាវីផ្តល់មេធាវីការពារក្តីជូនជនក្រីក្របានចំនួន ២៥៦៦ ករណី មានកូនក្តីសរុបចំនួន ៤០០០ នាក់ (ស្ត្រី ២៩១ នាក់) ក្នុងនោះរឿងក្តីអនីតិជនមានចំនួន ៨២៦ ករណី មានអនីតិជនសរុប ១០៨១ នាក់។ គណៈមេធាវីក៏បានផ្តល់កិច្ចពិគ្រោះយោបល់ច្បាប់ជូនជនក្រីក្របានចំនួន ២២៦ ករណីផងដែរ។ ដើម្បីឲ្យកិច្ចការផ្តល់សេវាកម្មផ្នែកច្បាប់ជូនជនក្រីក្របានរហ័សទាន់ពេលវេលា និងមានប្រសិទ្ធិភាព រាល់ការបញ្ជូនឯកសារស្នើសុំមេធាវីនិងលិខិតចាត់តាំងមេធាវី គឺធ្វើឡើងតាមប្រព័ន្ធតេឡេក្រាមជាបឋម ឯសំណៅដើមនឹងបញ្ជូនទៅពេលក្រោយ។ ក្នុងកិច្ចការគ្រប់គ្រងទិន្ន័យរឿងក្តីជនក្រីក្រ គឺធ្វើការគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានវិទ្យា។ គ្រប់ការិយាល័យប្រតិភូនីមួយៗត្រូវបានតម្លើងឱ្យប្រើប្រាស់នូវទិន្នន័យរួមនិងបញ្ជូនមកប្រព័ន្ធធំ(Center)នៅគណៈមេធាវី។ សមត្ថភាពនៃប្រព័ន្ធទិន្ន័យនេះ អាចឱ្យនាយកដ្ឋានដឹងអំពីសំណុំរឿងចាត់តាំងមេធាវីជូនជនក្រីក្រ លំហូរនីតិវិធីនៃសំណុំរឿងចំណាត់ការរបស់មេធាវីដែលទាំងអស់នេះ គឺជាចំណុចយ៉ាងសំខាន់សម្រាប់គណៈមេធាវីរៀបចំផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការការពារក្តីជូនជនក្រីក្រ។

ទន្ទឹមនឹងជួយការពារក្តីដល់ជនក្រីក្រ ក្នុងឆ្នាំ២០១៩ កន្លងមកនេះ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា តំណាងដោយលោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវី បានចុះអនុសារណៈនៃការយោគយល់ជាមួយក្រុមប្រឹក្សាជាតិ

ដើម្បីស្ត្រី ដើម្បីពង្រឹងសមត្ថភាព ដល់មន្ត្រីជំនាញនៃគណៈកម្មការអចិន្ត្រៃយ៍របស់ប្រឹក្សាជាតិដើម្បីស្ត្រីនិងជួយការពារផ្លូវច្បាប់ដល់ស្ត្រី និងក្មេងស្រីក្រីក្រដែលរងគ្រោះដោយសារអំពើហិង្សា ដោយផ្តោតលើអំពើហិង្សាក្នុងគ្រួសារ អំពើរំលោភសេពសន្ថវៈ និងអំពើជួញដូរ និងការធ្វើអាជីវកម្មផ្លូវភេទ។ល។ គម្រោងជាមួយក្រុមប្រឹក្សាជាតិ ដើម្បីស្ត្រីនេះមានរយៈពេល ០២ ឆ្នាំ ហើយគណៈមេធាវីជាអ្នកផ្តល់នូវវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់មន្ត្រីអនុវត្តច្បាប់ និងជួយពង្រឹងសមត្ថភាពបន្ថែមទៀតដល់សហភាតាមេធាវីពាក់ព័ន្ធនឹងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ព្រមទាំងគោលការណ៍មួយចំនួនទៀតពាក់ព័ន្ធនឹងការការពារកុមាររងគ្រោះនិងយន្តការកុមារមេត្រីសម្រាប់កិច្ចគាំពារកុមារដែលប្រព្រឹត្តបទល្មើស។ កញ្ចប់ថវិកាដែលជួយគាំទ្រគម្រោងនេះ គឺជាកញ្ចប់ថវិការបស់រាជរដ្ឋាភិបាល តាមរយៈក្រសួងកិច្ចការនារី។




កិច្ចការខាងលើនេះ គឺជាកិច្ចខិតខំប្រឹងប្រែងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាក្នុង ការរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាលក្នុងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងតុលាការ ជាពិសេស ជួយរាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋតាមរយៈការការពារក្តីជូនជនក្រីក្រដោយឥតយកកម្រៃដើម្បីធានាបាននូវយុត្តិធម៌សង្គម។

# ២- ការបណ្តុះបណ្តាលមេធាវី



អនុលោមតាមអនុក្រឹត្យ លេខ ១៣០ អនក្រ.បក ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី គណៈមេធាវីបានបណ្តុះបណ្តាលមេធាវីបាន ១៧ ជំនាន់ ដែលមានសិស្សសរុបចំនួន ៨៨៩ នាក់ ក្នុងនោះមានមេធាវីស្ត្រីចំនួន ២២៥ នាក់ (គិតតាំង ពីឆ្នាំ១៩៩៥ មកដល់បច្ចុប្បន្ន)។ ការបណ្តុះបណ្តាលមានរយៈពេល០១ ឆ្នាំ និងតម្រូវឱ្យសិស្សធ្វើកម្មសិក្សាក្នុងវិស័យច្បាប់ ជាក់ស្តែងតាមស្ថាប័នតុលាការ រយៈពេល០១ឆ្នាំ មុននឹងក្លាយជាមេធាវីពេញសិទ្ធិ។

ទន្ទឹមនឹងនេះ គណៈមេធាវីបានធ្វើការបណ្តុះបណ្តាលសិក្ខាកាមមេធាវីដែលចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីបានចំនួន ៨ វគ្គ ដែលមានសិក្ខាកាមមេធាវី សរុបចំនួន ៧៣៤ នាក់ ក្នុងនោះមានមេធាវីស្ត្រីចំនួន ១៧៤ នាក់។



ចាប់ពីអាណត្តិទី១១មក កម្មវិធីសិក្សាត្រូវបានធ្វើទំនើបកម្ម ដើម្បីឱ្យឆ្លើយតបទៅនឹងការវិវត្តនៃសង្គម សេដ្ឋកិច្ច ជាពិសេស ឆ្លើយតបទៅនឹងវិធានច្បាប់អន្តរជាតិនានា ហើយសម្រាប់ការធ្វើសុក្រឹត

ការមេធាវីដែលចូលប្រកបវិជ្ជាជីវៈមេធាវីតាមរយៈបទពិសោធន៍ ការងារគណៈមេធាវីបានកែទម្រង់ស៊ីជំរៅផងដែរ ដោយបានបន្ថែម ម៉ោងបណ្តុះបណ្តាលពី៨០ ម៉ោង ដល់ ១៨០ ម៉ោង និង បញ្ចូលមុខវិជ្ជាសិក្សា សំខាន់ៗ ដូចជាបច្ចេកទេសការពារក្តី ការវិភាគច្បាប់ និងច្បាប់អន្តរជាតិ ដើម្បីពង្រឹងគុណភាពនិងសមត្ថភាពជំនាញពិតប្រាកដដល់មេធាវី។

បច្ចុប្បន្នគណៈមេធាវីមានមេធាវីសរុបចំនួន ២១៧១ រូប ក្នុងនោះមានមេធាវីពេញសិទ្ធិ ចំនួន ១៥៦៥ រូប (ស្ត្រី ៣៤២ រូប) មេធាវីកម្មសិក្សា ៣៩៨ រូប ស្ត្រី ១២៤ រូប មេធាវីសុំមិនប្រកប វិជ្ជាជីវៈ ១១២ រូប ស្ត្រី ១៦ រូប និងមេធាវីសុំនៅក្រៅបញ្ជី ២៧ រូប ស្ត្រី ៦ រូប)។

## ៣- ការផ្សព្វផ្សាយ អប់រំច្បាប់ និងការពង្រឹងសមត្ថភាពមេធាវី

គណៈមេធាវីបានយកចិត្តទុកដាក់ធ្វើការសហការផ្សព្វផ្សាយអំពីតួនាទីមេធាវី និងច្បាប់នានាក្នុងស្ថានីយ៍វិទ្យុ និងទូរទស្សន៍ ដើម្បីឱ្យ សាធារណជនបានយល់ដឹងកាន់តែប្រសើរ។ ទន្ទឹមនឹងនេះ គណៈមេធាវីបានយកចិត្តទុកដាក់ខ្ពស់លើការពង្រឹងសមត្ថភាពបន្ថែមដល់មេធាវីតាមរយៈការស្វែងរកកិច្ចសហការជាមួយក្រសួង ស្ថាប័ន និងដៃគូសហការនានា និងបានខិតខំស្វែងរកគ្រូឧទ្ទេសនាមល្បីៗទាំងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ ដើម្បីជួយបណ្តុះបណ្តាលដល់សិស្សមេធាវី និងសិក្ខាកាមមេធាវី តាមរយៈការបង្រៀនក្នុងថ្នាក់ ការរៀបចំជាសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងវេទិកានានា ក្នុងគោលដៅពង្រឹងសមត្ថភាពមេធាវី។

## ៤- គោលនយោបាយមូលនិធិសុខុមាលភាពរបស់មេធាវី

ក្នុងអាណត្តិទី១១ និងទី១២ គណៈមេធាវីបានរៀបចំគោលនយោបាយមូលនិធិសុខុមាលភាពរបស់មេធាវី ដែលជាសកម្មភាពថ្មីមួយមិនធ្លាប់មានពីមុនមក ក្នុងគោលបំណងជួយសម្រាលបន្ទុកហិរញ្ញវត្ថុដល់មេធាវី និងក្រុមគ្រួសារមេធាវី ដែលទទួលរង

ទុព្វលភាពឬមរណភាព ព្រមទាំងបង្ហាញសាមគ្គីភាព និងការយកចិត្តទុកដាក់របស់គណៈមេធាវី ចំពោះក្រុមគ្រួសារមេធាវីនៅក្នុងគ្រាលំបាក។ ប្រភពនៃមូលនិធិនេះ បានមកពីការកាត់ប្រាក់ភាគទាន សមាជិកភាពមេធាវីម្នាក់ៗចំនួន ៣ ដុល្លារអាមេរិក ក្នុងមួយត្រីមាស និងចំនួន ១០០ ដុល្លារអាមេរិក ពីប្រាក់ឧបត្ថម្ភចំនួន ២,០០០ ដុល្លារអាមេរិកពីមេធាវីដែលចូលប្រកបវិជ្ជាជីវៈតាមមាត្រា ៣២។

## ៥- ការធ្វើទំនើបកម្មប្រព័ន្ធទំនាក់ទំនងក្នុងក្របខណ្ឌស្ថាប័នគណៈមេធាវី

ចាប់តាំងពីអាណត្តិទី១១ ហើយបន្តអនុវត្តក្នុងអាណត្តិទី១២នេះទៀត គណៈមេធាវីបានបង្កើតអ៊ីម៉ែលឱ្យសមាជិក-សមាជិកាគណៈមេធាវីម្នាក់ៗដែលមានលក្ខណៈជាវិជ្ជាជីវៈមេធាវី ចងជាក្រុមសម្រាប់គណៈមេធាវីទាំងមូល និង មានសង្គតិភាពសម្រាប់សម្រួលដល់ទំនាក់ទំនងឱ្យបានឆាប់រហ័ស ហើយបានកាត់បន្ថយការចំណាយលើក្រដាស និងបុគ្គលិករត់សំបុត្រផងដែរ។ ទន្ទឹមនឹងនេះ គណៈមេធាវីបានធ្វើការកែសម្រួលគេហទំព័ររបស់គណៈមេធាវីឱ្យកាន់តែប្រសើរជាងមុន និងងាយស្រួលក្នុងការស្វែងរកអត្ថបទលិខិតបទដ្ឋានគតិយុត្ត និងព័ត៌មានផ្សេងៗ។ គណៈមេធាវីក៏បានរៀបចំប្រព័ន្ធគ្រប់គ្រង ឯកសាររដ្ឋបាល និងហិរញ្ញវត្ថុជាអេឡិចត្រូនិក តាមបែបទំនើប ដែលងាយស្រួលក្នុងការរក្សាទុកស្វែងរក និងមិនបាត់បង់។

## ៦- ប្រសិទ្ធភាពការងាររបស់ប្រតិភូគណៈមេធាវីប្រចាំរាជធានី-ខេត្ត

ដើម្បីជួយសម្រួលដល់ការប្រកបវិជ្ជាជីវៈមេធាវី ជាពិសេស ការការពារក្តីជូនជនក្រីតាមបណ្តារាជធានី-ខេត្ត ប្រធានគណៈមេធាវីអាណត្តិទី១១ និងទី១២ បានផ្តួចផ្តើមគំនិតរៀបចំឱ្យមានប្រតិភូគណៈមេធាវីប្រចាំរាជធានី-ខេត្ត ដែលមានភារកិច្ចសម្របសម្រួលការងារ និងដោះស្រាយបញ្ហាប្រឈមនានាក្នុងការប្រកបវិជ្ជាជីវៈមេធាវីជាមួយស្ថាប័នតុលាការ

និងស្ថាប័នពាក់ព័ន្ធ ព្រមទាំង ជួយសម្រួលដល់ការផ្តល់ប្រឹក្សាយោបល់ និងទទួលពាក្យសុំការពារក្តីជូនជនក្រីក្រក្នុងក្របខណ្ឌ ខេត្តរបស់ខ្លួន។

ប្រតិភូគណៈមេធាវីត្រូវបានបង្កើតឡើងក្នុងគោលបំណងទី (១) ជួយលើកិច្ចការការពារក្តីជូនជនក្រីក្របានទាន់ពេលវេលានិងមានគុណភាព ទី (២) ជាយន្តការមួយសម្រាប់តាមដានការអនុវត្តច្បាប់នៅតាមតុលាការដែលជាចំណែកមួយជួយរាជរដ្ឋាភិបាលក្នុងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌និងតុលាការ ទី (៣) ជាយន្តការសម្រួលដល់មេធាវីតាមបណ្តាខេត្តលើបញ្ហាប្រកបវិជ្ជាជីវៈមេធាវី និងទី (៤) ជាយន្តការបញ្ជ្រាបមេធាវីទៅគ្រប់បណ្តាខេត្ត ជាពិសេស ខេត្តដាច់ស្រយាលដែលមិនមានមេធាវីទៅប្រកបវិជ្ជាជីវៈនៅទីនោះសម្រាប់គាំទ្រសេវាយុត្តិធម៌សង្គម។

ក្នុងគោលគំនិតខាងលើនេះ ការិយាល័យប្រតិភូគណៈមេធាវីប្រចាំរាជធានី-ខេត្ត ត្រូវបានបង្កើតនៅទូទាំងប្រទេសនៅតាមសាលាដំបូងរាជធានី-ខេត្ត និងនៅសាលាឧទ្ធរណ៍។

ការិយាល័យប្រតិភូនីមួយៗ មានជំនួយការមួយរូបជាសេនាធិការ និងបានបំពេញការងារដោយចាត់តាំងមេធាវីការពារក្តីជូនជនក្រីក្របានទាន់ពេលវេលាតាមការស្នើសុំរបស់តុលាការ ព្រមទាំងបានចូលរួមពិគ្រោះយោបល់ជូនប្រជាពលរដ្ឋយ៉ាងសកម្ម។ យន្តការប្រតិភូគណៈមេធាវីនេះ ត្រូវបានក្រសួងយុត្តិធម៌ និងតុលាការទទួលស្គាល់ និងសហការយ៉ាងពេញទំហឹងក្នុងកិច្ចការងារជួយជនក្រីក្រ។

## ៧- ការបង្កើតឱ្យមានបន្ទប់មេធាវីជួបប្រាស្រ័យកូនក្តីតាមពន្ធនាគាររាជធានី-ខេត្ត

ដោយមានការឯកភាពពី **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី** និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គណៈមេធាវីបានសហការជាមួយអគ្គនាយកដ្ឋានពន្ធនាគារ

ក្រសួងមហាផ្ទៃ សាងសង់បន្ទប់សម្រាប់មេធាវីជួបសម្ភាសន៍កូនក្តីនៅគ្រប់ពន្ធនាគារទូទាំងប្រទេស។ ថវិកាសាងសង់នេះ គឺមានការគាំទ្រ និងឧបត្ថម្ភដ៏ខ្ពង់ខ្ពស់ពីសំណាក់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចំនួន ៧ ម៉ឺនដុល្លារអាមេរិក។ ថវិកានៅសល់ ៧ ម៉ឺនដុល្លារអាមេរិកទៀត គឺបានមកពីការរៃអង្គាសពីសមាជិកគណៈមេធាវី។ ដំណើរការសាងសង់បានចាប់ផ្តើមក្នុងឆ្នាំ២០១៨ ហើយបច្ចុប្បន្ននេះ បន្ទប់មេធាវីនៅតាមពន្ធនាគារសម្រេចបានការសាងសង់រួចរាល់ជាស្ថាពរហើយ។

## ៨- ការផ្តល់មេធាវីជួយការពារក្តីក្នុងយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿង

ក្នុងយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមតុលាការ គណៈមេធាវីបានជូនដំណឹងដល់សមាជិក-សមាជិកាគណៈមេធាវី មេធាវីកម្មសិក្សា និងប្រតិភូគណៈមេធាវីគ្រប់រាជធានី-ខេត្តដើម្បីចូលរួមជាមួយនឹងរាជរដ្ឋាភិបាលលើកិច្ចការងារនេះ។ បច្ចុប្បន្ន គណៈមេធាវីកំពុងធ្វើកិច្ចការងារនេះយ៉ាងសកម្មក្នុងស្មារតីទទួលខុសត្រូវខ្ពស់ជាមួយនឹងស្ថាប័នតុលាការ។

## ៩- ការធ្វើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

គោរពតាមការសម្រេចរបស់រាជរដ្ឋាភិបាល គណៈមេធាវីបានបង្កើតក្រុមការងារជំនាញ ដើម្បីពិនិត្យ និងរៀបចំខ្លឹមសារដែលត្រូវធ្វើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ក្រុមការងារនេះ បានចូលរួមប្រជុំជាបន្តបន្ទាប់ តាមការអញ្ជើញរបស់ឯកឧត្តម អង្គ វង្សវឌ្ឍានា អតីតរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងាររៀបចំ ការធ្វើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនាពេលនោះ ព្រមទាំងឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលជាសហប្រធាន។ បច្ចុប្បន្ននេះ សេចក្តីព្រាងច្បាប់នេះកំពុងស្ថិត

នៅក្នុងក្រុមការងារជំនាញនៃក្រសួងយុត្តិធម៌ បន្ទាប់ពីក្រុមការងារជំនាញនៃគណៈមេធាវី បានពិនិត្យ និងជូនយោបល់រួចរាល់។

## ១០-ការសម្រេចឱ្យមានអាវវិជ្ជាជីវៈមេធាវីសម្រាប់ថ្នាក់ដឹកនាំគណៈមេធាវី

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចដាក់ឱ្យប្រើជាផ្លូវការនូវប្រភេទអាវ សម្រាប់មេធាវីប្រើប្រាស់ក្នុងកម្មវិធីផ្លូវការរបស់គណៈមេធាវី។ ការកំណត់ឱ្យប្រើប្រាស់ប្រភេទអាវ ទាំងនេះក្នុងគោលបំណងពង្រឹងនិងលើកតម្កើងកិត្យានុភាពនៃវិជ្ជាជីវៈមេធាវី ព្រមទាំងគណៈមេធាវី ដែលជាស្ថាប័នឯករាជ្យ ក៏ដូចជាការលើកទឹកចិត្តដល់សមាជិក-សមាជិកាទាំងឡាយដែលបានបំពេញ ការងារលើសពី ១៥ ឆ្នាំ ប្រកបដោយក្រមសីលធម៌ វិជ្ជាជីវៈល្អ។ សេចក្តីសម្រេចលេខ៣៦៩/សស គម/១៩ បានកំណត់អាវសម្រាប់មេធាវី ជា៦ប្រភេទ គឺអាវសម្រាប់ប្រធានគណៈមេធាវី អាវសម្រាប់ អតីតប្រធានគណៈមេធាវី អាវសម្រាប់សមាជិកក្រុមប្រឹក្សាគណៈមេធាវី អាវសម្រាប់អតីតសមាជិក ក្រុមប្រឹក្សាគណៈមេធាវី អាវសម្រាប់មេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាប់ពី ១៥ ឆ្នាំ ឡើងទៅ និងអាវវិជ្ជាជីវៈមេធាវី។ ប្រភេទអាវថ្មីទាំងនេះ ត្រូវអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់តែក្នុង កម្មវិធីផ្លូវការរបស់គណៈមេធាវីប៉ុណ្ណោះ ចំណែកការអនុវត្តការងារក្នុងវិជ្ជាជីវៈប្រចាំថ្ងៃនៅតុលាការ មេធាវីគ្រប់រូបត្រូវប្រើអាវវិជ្ជាជីវៈមេធាវីរួមដដែល។

## ១១- ការចូលរួមជាមួយនឹងរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃកូវីដ ១៩

ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃកូវីដ ១៩គណៈមេធាវីបានរៃអង្គាសថវិកាពីសមាជិក-សមាជិកាគណៈមេធាវី សប្បុរសជននានា សរុបបានចំនួន ២៣,៥៨០.៩៩ ដុល្លារអាមេរិក និង៥,៩៧៨,០០០ រៀល ប្រគល់ជូនរាជ

រដ្ឋាភិបាល។ ទន្ទឹមនឹងនេះ ដោយអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល នៅទីស្នាក់ការគណៈមេធាវី បានបំពាក់ម៉ាស៊ីនសម្លាប់មេរោគដែលជាទូភ្ជាប់ប្រព័ន្ធបាញ់ទឹកថ្នាំសម្លាប់មេរោគពេញដងខ្លួនខាងក្រៅ ទឹកអាល់កុលលាងដៃ និងឧបករណ៍វាស់សីតុណ្ហភាព ធ្វើឱ្យមានទំនុកចិត្តពីសហភាតាមេធាវី សិស្សមេធាវី សាស្ត្រាចារ្យ បុគ្គលិក និងអតិថិជនដែលមករកសេវានានាពីគណៈមេធាវី។

ក្នុងការរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃវីរុសកូវីដ ១៩ នេះផងដែរ គណៈមេធាវីបានសម្រេចឱ្យមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី បន្តបណ្ដុះបណ្ដាលសិស្សមេធាវីជំនាន់ទី១៧ និងធ្វើការប្រឡងនានា ព្រមទាំងការប្រឡងបញ្ចប់ តាមរយៈប្រព័ន្ធអនឡាញ។

## ១២- ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងគណៈមេធាវី និង ក្រសួងស្ថាប័នរដ្ឋ ព្រមទាំង ដៃគូជាតិ និងអន្តរជាតិនានា

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានខិតខំកសាងទំនាក់ទំនងល្អជាមួយនឹងក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋពាក់ព័ន្ធ ជាអាទិ៍ ក្រុមប្រឹក្សាធម្មនុញ្ញ ព្រឹទ្ធសភា ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងបរិស្ថាន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងកិច្ចការនារី ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ អង្គភាពប្រឆាំងអំពើពុករលួយ កងរាជអាវុធហត្ថលើផ្ទៃប្រទេស សភាពាណិជ្ជកម្មកម្ពុជា ស្ថានទូតនានាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងដៃគូក្នុងវិស័យឯកជនមួយចំនួនទៀត។

កិច្ចសហប្រតិបត្តិការនេះ គឺធ្វើឡើងក្នុងរូបភាពជាការជួយគ្នាទៅវិញទៅមកក្នុងវិស័យច្បាប់ និងការរៀបចំសិក្ខាសាលារួមគ្នា ដើម្បីផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តិនានារបស់រាជរដ្ឋាភិបាល ធ្វើយ៉ាងណារួមគ្នាពង្រឹងការអនុវត្តច្បាប់ ដែលជាមូលដ្ឋានគ្រឹះនៃនីតិរដ្ឋ។

## ១៣- ការបង្កើតគណៈកម្មការកីឡាគណៈមេធាវី

ទន្ទឹមនឹងការអនុវត្តគោលនយោបាយសុខុមាលភាពរបស់មេធាវី កន្លងមកគណៈមេធាវីបានបង្កើតគណៈកម្មការកីឡាគណៈមេធាវី ដែលរហូតមកដល់បច្ចុប្បន្ននេះ គណៈកម្មការកីឡានេះ បានបន្តសកម្មភាពយ៉ាងសកម្ម ដើម្បីពង្រឹងសុខភាពមេធាវី និងពង្រឹង



សាមគ្គីភាពមេធាវី ព្រមទាំងទំនាក់ទំនងកិច្ចសហប្រតិបត្តិល្អជាមួយក្រសួង ស្ថាប័ន និងអង្គការនានាតាមរយៈ សកម្មភាពប្រកួតកីឡា។ ចំណែកឯថវិកាសម្រាប់ដំណើរការគណៈកម្មការកីឡាគណៈមេធាវី គឺបានមកពីគណៈមេធាវី និងជំនួយឧបត្ថមពីសមាជិក-សមាជិកាគណៈមេធាវី ព្រមទាំងសប្បុរសជននានា ។

## ១៤- ការបង្កើតបទភ្លេងអត្តសញ្ញាណគណៈមេធាវី

ដោយមើលឃើញពីបទពិសោធន៍គណៈមេធាវីនៃបណ្តាប្រទេសដទៃ គណៈមេធាវីបានសម្រេចបង្កើតបទភ្លេងសម្រាប់គណៈមេធាវី និងបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅក្នុងឱកាសនៃមហាសន្និបាតរបស់គណៈមេធាវី ពិធីបុណ្យ និងពិធីផ្លូវការផ្សេងទៀតរបស់គណៈមេធាវី។ បទភ្លេងនេះ ជាសារសំឡេងបញ្ជូនដល់គ្រប់សមាជិក-សមាជិកាគណៈមេធាវី និងភ្ញៀវមកពីក្រសួងស្ថាប័នពាក់ព័ន្ធនានាដែលចូលរួមកម្មវិធី

របស់គណៈមេធាវី បានស្គាល់ពីតម្លៃនៃវិជ្ជាជីវៈមេធាវី ចងចាំ និងរំលឹកដាស់តឿនដល់សហភាតាមេធាវីអំពីតម្លៃជាមេធាវី និងកិត្យានុភាពរបស់ស្ថាប័នគណៈមេធាវី ជៀសវាងការអនុវត្តវិជ្ជាជីវៈប្រាសចាសពីច្បាប់ និងវិធានវិជ្ជាជីវៈ ជាហេតុធ្វើឲ្យកិត្តិយសរបស់ស្ថាប័នគណៈមេធាវី ព្រមទាំងតម្លៃជាមេធាវីធ្លាក់ចុះ។

## ១៥- ការចុះអនុស្សរណៈយោគយល់រវាងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងសភាពាណិជ្ជកម្មកម្ពុជា



គណៈមេធាវីបានភ្ជាប់ទំនាក់ទំនងស្ថាប័នគណៈមេធាវីជាមួយនឹងសភាពាណិជ្ជកម្មកម្ពុជា កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ តាមរយៈអនុស្សរណៈនៃការយោគយល់មួយ ក្នុងគោលដៅផ្លាស់ប្តូរបទពិសោធន៍និងចែករំលែកព័ត៌មានក្នុងវិស័យពាណិជ្ជកម្ម និងច្បាប់។

## ១៦- គណៈកម្មការវិន័យនៃក្រុមប្រឹក្សាគណៈមេធាវី

គណៈកម្មការវិន័យនៃក្រុមប្រឹក្សាគណៈមេធាវីត្រូវបានបង្កើតឡើង ដើម្បីជំនុំជម្រះវិវាទនានាពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈមេធាវី។ សមាជិកនៃក្រុមប្រឹក្សាវិន័យ គឺសុទ្ធសឹងតែជាសមាជិកក្រុមប្រឹក្សាគណៈមេធាវី។ យន្តការនេះគឺជួយសម្រួលកិច្ចការងាររបស់ក្រុមប្រឹក្សាគណៈមេធាវី ក្នុងការសម្រេចសេចក្តីនានាពាក់ព័ន្ធនឹងវិជ្ជាជីវៈ។

គណៈមេធាវីបានសម្រេចបង្កើតលេខាធិការដ្ឋានទទួលបណ្តឹង និងដោះស្រាយវិវាទនៃគណៈកម្មការវិន័យ ដែលមាននាយកដ្ឋានអធិការកិច្ចជាសេនាធិការ តាមសេចក្តីសម្រេចលេខ២៩៤/សសគម/១៩ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩។

ការបង្កើតឱ្យមានលេខាធិការដ្ឋាននេះ បានសម្រួលដល់នាយកដ្ឋានអធិការកិច្ចក្នុងការដោះស្រាយវិវាទនិងទទួលបណ្តឹងពីមេធាវី ឬពីភាគីណាមួយនៃបណ្តឹង។ ការិយាល័យទទួលពាក្យបណ្តឹង បានទទួលសំណុំរឿងសរុបទាំងអស់ចំនួន ៣២២ សំណុំរឿង (ដែលសំណុំរឿងស្នើសុំអន្តរាគមន៍មានចំនួន ២១៥ និងសំណុំរឿងទាមទារសំណង និងសុំដាក់វិន័យមេធាវីមានចំនួន១០៧ ហើយសំណុំរឿងទាំងនោះ មានចាប់តាំងពីឆ្នាំ១៩៩៦ រហូតដល់បច្ចុប្បន្ន) បានចុះបញ្ជីរួចអស់ហើយ បច្ចុប្បន្នសំណុំរឿងដែលបានបិទបញ្ចប់ និងចុះបញ្ជីបិទរួចមានចំនួន ៩៨ សំណុំរឿង។ សំនុំរឿងដែលការិយាល័យធ្វើការសម្រុះសម្រួល និងកំពុងធ្វើការអន្តរាគមន៍បច្ចុប្បន្នមានចំនួន១៦០ សំណុំរឿងទៀត។

ការិយាល័យទទួលពាក្យបណ្តឹង និងអង្កេតទូទៅ បានអញ្ជើញភាគីមកធ្វើការផ្សះផ្សារ ចំនួន១២ សំណុំរឿង ហើយ១សំណុំរឿងបានបញ្ចប់ដោយភាគីសះជាគ្នា និង ០១ករណីទៀតសុំដកពាក្យបណ្តឹងវិញ។ ចំណែកឯ១១សំណុំរឿងទៀតមិនទាន់បញ្ចប់នៅឡើយ។

ក្នុងចំណោមសំណុំរឿងទាំងអស់ មានសំណុំរឿងចំនួនបីបានដំណើរការនីតិវិធីឈានដល់ដំណាក់កាលជំនុំជម្រះ។

## ១៧- ការទទួលបានអគារទាំងមូលសម្រាប់គណៈមេធាវ

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានសម្រេចប្រគល់ចំណែកនៃអគារមជ្ឈមណ្ឌលតម្កល់ឯកសាររបស់សាលាក្តីខ្មែរក្រហមជូនគណៈមេធាវី ដើម្បីសម្រួលដល់ការបំពេញការងារគណៈមេធាវីឲ្យកាន់តែល្អប្រសើរឡើងថែមទៀត។ គណៈមេធាវីបានជួសជុល និងកែលម្អចំណែកអគារដែលបានទទួលនេះឲ្យស្របតាមស្តង់ដារបច្ចេកទេសទំនើបទាំងកៅអីអង្គុយ និងតុប្រជុំ ព្រមទាំងឧបករណ៍បំពាក់នានាសម្រាប់ទ្រទ្រង់ដល់ដំណើរការប្រជុំ។

គណៈមេធាវីក៏បានសម្រេចដាក់ឲ្យមជ្ឈមណ្ឌលតាំងនៅជាមួយទីស្នាក់ការគណៈមេធាវី ដោយមានរៀបចំជាបន្ទប់សិក្សា និងបន្ទប់សវនាការត្រាប់ ព្រមទាំងបានដំណើរការបណ្តុះបណ្តាលជាបន្តបន្ទាប់ ទៅតាមកាលវិភាគសិក្សា នៅលើទីតាំងថ្មីនេះ។ ក្រៅពីរៀបចំបន្ទប់សម្រាប់នាយកដ្ឋានជំនាញនីមួយៗ ដើម្បីសម្រួលដល់ការបំពេញកិច្ចការងាររបស់បុគ្គលិកគណៈមេធាវី និងសម្រួលផងដែរដល់សហភាគា និងភ្ញៀវនានាដែលមកប្រើ




ប្រាស់សេវាផ្សេងៗនៅគណៈមេធាវី យើងក៏បានរៀបចំឲ្យមានអាហារដ្ឋាននៅក្នុងទីតាំងនៃគណៈមេធាវី ដើម្បីសម្រួលដល់សិស្សមេធាវី បុគ្គលិកគណៈមេធាវី និងសាធារណជនដែលមកប្រើប្រាស់សេវាផ្សេងៗនៅគណៈមេធាវីផងដែរ។

## ១៨- ការកំណត់ពីការប្រើប្រាស់ត្រារបស់ការិយាល័យមេធាវី ក្រុមមេធាវី និងក្រុមហ៊ុនមេធាវី

ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌មេធាវី បានកំណត់បែបបទនៃការអនុវត្តវិជ្ជាជីវៈមេធាវី។ ការគ្រប់គ្រងលំនៅវិជ្ជាជីវៈ គឺមានសណ្ឋានផ្សេងៗគ្នា ទៅតាមបច្ចេកទេស និងគំនិតរបស់ប្រធាននៃការិយាល័យមេធាវី ក្រុមមេធាវី និងក្រុម

ហ៊ុនមេធាវី ហើយការប្រើប្រាស់ត្រាសម្គាល់ការិយាល័យមេធាវី មានទម្រង់ផ្សេងៗគ្នា ពីព្រោះបទប្បញ្ញត្តិគ្រប់គ្រងវិជ្ជាជីវៈមេធាវីមិនទាន់បានកំណត់ពីការប្រើប្រាស់ត្រាបែបនេះនៅឡើយ។ ដើម្បីរៀបចំការប្រកបវិជ្ជាជីវៈមេធាវីឲ្យកាន់តែល្អប្រសើរ និងបង្កើនទំនុកចិត្តពីអតិថិជន គណៈមេធាវីបានកំណត់ពីការប្រើប្រាស់ត្រាសម្គាល់ការិយាល័យមេធាវី ក្រុមមេធាវី និងក្រុមហ៊ុនមេធាវី ដែលបានចុះបញ្ជីស្របច្បាប់នៅគណៈមេធាវី។ មេធាវីអាចដាក់ពាក្យសុំប្រើប្រាស់ត្រាមកគណៈមេធាវី ភ្ជាប់គំរូត្រារបស់ខ្លួនដែលត្រូវគោរពតាមខ្នាត និងទម្រង់ដែលគណៈមេធាវីបានកំណត់។

## ១៩- ការចូលរួមក្នុងសកម្មភាពសង្គម



ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងស្ថាប័នគណៈមេធាវី និងសង្គម ថ្នាក់ដឹកនាំគណៈមេធាវី បានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពសង្គម មានជាអាទិ៍ បានអញ្ជើញចូលរួមដាក់កម្រងផ្កា គោរពវិញ្ញាណក្ខន្ធសពអ្នកឧកញ៉ាព្រឹទ្ធមហាឧបាសិកាធម្មញ្ញាណវិវឌ្ឍនា ប៊ុន ស៊ាងលី មាតាក្មេក **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងបានចូលរួមចំណែករំលែកទុក្ខញាតិនៃសហភាតាមេធាវីមួយចំនួន ដែលបានចែកឋាន។ ទន្ទឹមនឹងនេះ ថ្នាក់ដឹកនាំគណៈមេធាវីក៏បានចូលរួមយ៉ាងសកម្មផងដែរក្នុងកម្មវិធីសង្គមនានា ដូចជា ពិធីបុណ្យកឋិនទាន ពិធីមង្គលការ ពិធីជួបជុំនានា ដែលរៀបចំឡើងដោយសហភាតាមេធាវី។

ឥឥឥឥឥ❈ឲឲឲឲឲ

# បញ្ហាប្រឈមដែលគណៈមេធាវីជួបប្រទះ

ទន្ទឹមនឹងសមិទ្ធផលដ៏ល្អប្រសើរដែលគណៈមេធាវីទទួលបានក្នុងឆ្នាំកន្លងទៅនេះ គណៈមេធាវីក៏បានពើបប្រទះផងដែរនូវបញ្ហាប្រឈមមួយចំនួន ដូចជា៖

- ករណីមេធាវីប្រមូលផ្តុំនៅតែរាជធានី និងទីរួមខេត្តដែលមានសក្តានុពលសេដ្ឋកិច្ច ធ្វើឱ្យមានកង្វះខាតសេវាមេធាវីនៅតាមបណ្តាខេត្ត និងតំបន់ដាច់ស្រយាល
- សមត្ថភាពរបស់មេធាវីក្នុងការប្រកួតប្រជែងនៅក្នុងទីផ្សារវិជ្ជាជីវៈនៅមានកម្រិត ស្របពេលនៃការធ្វើសាកលភាវូបនីយកម្ម និងសមាហរណកម្មក្នុងអាស៊ាន និងអន្តរជាតិ។ វត្តមានអ្នកវិនិយោគពីបរទេសមានការកើនឡើងធ្វើឱ្យតម្រូវការប្រើប្រាស់មេធាវីជំនាញកាន់តែច្រើន។ បញ្ហាភាសានិងភាព ទាន់សម័យនៃបច្ចេកវិទ្យា គឺជាឧបសគ្គចំបង។ មេធាវីមួយចំនួនមិនទាន់អាចប្រើប្រាស់ភាសាបរទេសបាន ហើយមិនអាចប្រើប្រាស់មធ្យោបាយទំនាក់ទំនងឆាប់រហ័ស ដូចជា អ៊ីម៉ែល ឬមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិចផ្សេងទៀត ដែលធ្វើឱ្យខាតបង់ពេលវេលា និងមិនអាចឆ្លើយតបទាន់សភាពការណ៍ និងតម្រូវការក្នុងការអនុវត្តសេវាកម្មមេធាវីបាន។
- សកម្មភាពការពារក្តីជូនជនក្រីក្រ ជួបប្រទះនូវបញ្ហាខ្វះខាតថវិកា ដោយសារតែអង្គការ និងសមាគមដែលធ្លាប់តែផ្តល់សេវាផ្នែកច្បាប់ បានបន្ថយ និងផ្អាកសកម្មភាពទាំងស្រុង ធ្វើឱ្យការផ្តល់សេវាមេធាវីការពារក្តីជូនជនក្រីក្រទូទាំងប្រទេស ជាបន្ទុករបស់គណៈមេធាវីទាំងស្រុង។ ចំនួនរឿងក្តីក្រីក្រដែលស្នើសុំមកគណៈមេធាវីនៅក្នុងឆ្នាំ ២០២០ មានការកើនឡើងយ៉ាងគំហុកបើប្រៀប

ជៀបនឹង ឆ្នាំ២០១៩ ដោយសារតែប្រជាពលរដ្ឋយល់ដឹងកាន់តែច្បាស់និងស៊ីជំរៅពីតួនាទីមេធាវីក្នុងសង្គម និងសិទ្ធិនានា របស់ខ្លួនក្នុងប្រព័ន្ធយុត្តិធម៌។

- សិទ្ធិមួយចំនួនរបស់មេធាវីត្រូវបានបំពាន ហើយកិច្ចការមួយចំនួនរបស់មេធាវីត្រូវគេធ្វើតាមរយៈអន្តរការី នៅតាមស្ថាប័នមួយចំនួន ដូចជា នៅតុលាការ មន្ទីរសុរិយោដី និងក្រសួងពាណិជ្ជកម្ម។ល។
- ការអនុវត្តកាតព្វកិច្ចបង់ភាគទានរបស់សមាជិក-សមាជិកាគណៈមេធាវីមួយចំនួនតូចមិនទាន់ពេលវេលា។ មួយចំនួនទៀតមិនព្រមបំពេញកាតព្វ កិច្ចបង់ភាគទានដែលបង្ហាញឱ្យឃើញនូវការមិនយកចិត្តទុកដាក់ និងមិនជ្រោមជ្រែងដល់វិជ្ជាជីវៈរបស់ខ្លួន។
- កង្វះខាតការចូលរួមពីសហភាគា ដូចជាការបញ្ចេញមតិយោបល់លើប្រធានបទដែលគណៈមេធាវីស្នើឲ្យសហភាគាទាំងអស់រួមចំណែកជួយ ដើម្បីជាប្រយោជន៍រួមនៃវិជ្ជាជីវៈមេធាវី។

ៜៜៜៜៜ✵ៜៜៜៜៜ

## ទិសដៅអនុវត្តបន្ត

ដើម្បីបន្តនិរន្តរភាពវិជ្ជាជីវៈមេធាវី និងលើកកម្ពស់កិត្យានុភាពរបស់គណៈមេធាវីនៅក្នុងសង្គម គណៈមេធាវីបានកំណត់ទិសដៅអនុវត្តបន្តដូចតទៅ៖

- បន្តរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាលក្នុងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងតុលាការ
- បន្តលើកទឹកចិត្តឱ្យមានមេធាវីបម្រើការងារនៅគ្រប់ខេត្ត ជាពិសេស ខេត្តដាច់ស្រយាល
- បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ក្រមសីលធម៌ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចផ្សេងៗរបស់គណៈមេធាវីឱ្យមានប្រសិទ្ធភាពខ្ពស់
- បន្តពិនិត្យនិងពិភាក្សាលើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដើម្បីធ្វើវិសោធនកម្មច្បាប់នេះ ស្របតាមបច្ចុប្បន្នភាពនៃសង្គម
- បន្តសកម្មភាពរបស់ក្រុមការងារសិក្សាលើក្រមទាំងបួន ដើម្បីស្នើទៅក្រសួងស្ថាប័នពាក់ព័ន្ធ រៀបចំសេចក្តីព្រៀងវិសោធនកម្ម
- បន្តពិនិត្យ តាមដាន និងមានវិធានការចំពោះការអនុវត្តវិជ្ជាជីវៈមេធាវី ដែលមិនគោរពតាមច្បាប់ និងវិធានរបស់គណៈមេធាវី ដូចជា ការចូលរួមសវនាការបង្គ្រប់កិច្ច និងការប្រគល់សិទ្ធិជាអនុតំណាង ដោយពុំមានការយល់ព្រមពីកូនក្តីជាដើម
- បន្តអនុវត្តគោលនយោបាយមូលនិធិសុខុមាលភាពមេធាវី ដើម្បីជួយសម្រាលទុក្ខលំបាករបស់មេធាវី
- បន្តពង្រឹងកិច្ចការពារក្តីជូនជនក្រីក្រ និងការងារប្រតិភូគណៈមេធាវីនៅទូទាំងប្រទេស ជាពិសេសតាមបណ្តាខេត្ត និងជនបទដាច់ស្រយាល
- ពិនិត្យ និងសម្រេចលើពាក្យស្នើសុំចុះបញ្ជីប្រកបវិជ្ជាជីវៈរបស់មេធាវីបរទេសដែលបំពេញគ្រប់លក្ខខណ្ឌសម្រាប់ការចុះបញ្ជី និងចាត់វិធានការចំពោះជន

បរទេសទាំងឡាយដែលអនុវត្តវិជ្ជាជីវៈមេធាវី ដោយខុសច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា

- បន្តផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹង និងការទទួលស្គាល់ពីតួនាទីរបស់មេធាវី នៅក្នុងសង្គម ទៅកាន់ស្ថាប័ននានា និងសាធារណជន
- បន្តពិនិត្យ តាមដាន និងការពារការអនុវត្តវិជ្ជាជីវៈមេធាវីស្របតាមច្បាប់ជាធរមាន
- បន្តការពារមេធាវីពីការចាប់ខ្លួន ឃុំខ្លួន និងចោទប្រកាន់ដោយបំពានច្បាប់ និងវិធានវិជ្ជាជីវៈមេធាវី
- បន្តពង្រឹងគុណភាព និងសមត្ថភាពមេធាវី តាមរយៈការបណ្តុះបណ្តាលបន្តដើម្បីឆ្លើយតបនឹងការវិវឌ្ឍសង្គម សេដ្ឋកិច្ច និងចរន្តនៃសកលភាវូបនីយកម្ម
- បន្តរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលបន្តដល់មេធាវីដែលកំពុងប្រកបវិជ្ជាជីវៈ ដើម្បីបង្កើននូវចំណេះដឹង និងពង្រឹងសមត្ថភាពមេធាវី ស្របនឹងការវិវឌ្ឍរបស់សង្គម និងការធ្វើសមាហរណកម្មក្នុងតំបន់អាស៊ាន
- ស្វែងរកឱកាសសិក្សា និងផ្តល់ការលើកទឹកចិត្ត សម្រាប់មេធាវីដែលមានបំណងបន្តការសិក្សារបស់ខ្លួននៅថ្នាក់ក្រោយឧត្តមសិក្សា និងបង្កើនឱកាសដល់មេធាវី ដើម្បីធ្វើទស្សនកិច្ចសិក្សា និង/ឬ ទទួលបានអាហារូបករណ៍ ដើម្បីបន្តការសិក្សានៅបរទេស
- បន្តដោះស្រាយវិវាទរវាងមេធាវី និងមេធាវី រវាងមេធាវី និងអតិថិជន ដែលបានប្តឹងមកគណៈមេធាវី តាមរយៈយន្តការថ្មី នៃគណៈកម្មការវិន័យនៃក្រុមប្រឹក្សាគណៈមេធាវី
- បន្តចាត់វិធានការទៅតាមផ្លូវច្បាប់ចំពោះជនដែលប្រកបវិជ្ជាជីវៈខុសច្បាប់
- បន្តជំរុញសិទ្ធិទទួលបានយុត្តិធម៌របស់កុមារ និងស្ត្រី
- បន្តធ្វើបច្ចុប្បន្នភាពវិធានវិជ្ជាជីវៈឱ្យទាន់តាមការវិវឌ្ឍរបស់សង្គម

- បន្តពង្រឹងគុណភាពនៃការផ្សព្វផ្សាយ អប់រំច្បាប់ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសាធារណៈ
- បន្តធ្វើបច្ចុប្បន្នភាពច្បាប់ និងបទដ្ឋានគតិយុត្តនានា នៅលើគេហទំព័រគណៈ-មេធាវី ដើម្បីជាទុនក្នុងការស្រាវជ្រាវរបស់សមាជិកគណៈមេធាវី
- បន្តពង្រីកកិច្ចសហការរវាងស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីពង្រឹងការអនុវត្តច្បាប់ និងវិជ្ជាជីវៈមេធាវី ឱ្យបានកាន់តែប្រសើរឡើង
- បន្តកិច្ចសហការជាមួយស្ថាប័នគណៈមេធាវីបរទេស ដើម្បីចែករំលែកបទពិសោធន៍ល្អក្នុងការគ្រប់គ្រងវិជ្ជាជីវៈមេធាវីនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បន្តជំរុញការផ្សព្វផ្សាយវិជ្ជាជីវៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ទាំងលើឆាកជាតិ និងឆាកអន្តរជាតិ។

# សេចក្តីសន្និដ្ឋាន

ចាប់តាំងពីខែតុលា ឆ្នាំ២០១៩ ដល់ខែតុលា ឆ្នាំ២០២០ នេះ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សម្រេចបាននូវសមិទ្ធផលជាច្រើនគួរជាទីមោទនៈ សម្រាប់ជាប្រយោជន៍ដល់ការលើកកម្ពស់វិជ្ជាជីវៈមេធាវី និងស្ថាប័នគណៈមេធាវី។

សមិទ្ធផលនិងជោគជ័យទាំងនេះ កើតចេញពីការខិតខំប្រឹងប្រែងរួមគ្នាពីសំណាក់ប្រធានគណៈមេធាវី ក្រុមប្រឹក្សាគណៈមេធាវី អគ្គលេខាធិការ នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី និងបុគ្គលិករបស់គណៈមេធាវី ក្រោមការចូលរួមចំណែកពីសមាជិកសមាជិកាគណៈមេធាវីទាំងអស់។

គណៈមេធាវីសង្ឃឹម និងជឿជាក់ថា ប្រធានគណៈមេធាវីបន្តវេនក្នុងអាណត្តិបន្ទាប់ទៀត នឹងបន្តនូវបេសកកម្មចំបងៗរបស់គណៈមេធាវី បូករួមគំនិតដឹកនាំថ្មីៗ ក្រោមការគាំទ្រពីក្រុមប្រឹក្សាគណៈមេធាវី និងសហភាតាទាំងអស់ ដើម្បីជាប្រយោជន៍រួមដល់ស្ថាប័នគណៈមេធាវី មេធាវីខ្លួនឯង និងសង្គមជាតិទាំងមូល៕

ថ្ងៃពុធ ១២រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០

អគ្គលេខាធិការ

មេធាវី ព្រហ្ម វិចិត្រអក្ខរា

ថ្ងៃពុធ ១២រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០

បានឃើញ និងឯកភាព

ប្រធានគណៈមេធាវី

មេធាវី សួន វិសាល